| | | | |
|---|---|---|---|
| ១៦-លោក | ឈេង ហាក់ | ទឹកប្រាក់ | ១០.០០០ USD |
| ១៧-លោក | ម៉ៅ គឹម | ទឹកប្រាក់ | ១៦.០០០ USD |
| ១៨-លោកស្រី | ខួត គឹមយឿន | ទឹកប្រាក់ | ១២.០០០ USD |
| ១៩-លោក | ស៊ីវន្ត សាម៉ន | ទឹកប្រាក់ | ១០.៥០០ USD |
| ២០-លោកស្រី | សុខ សម្បត្តិ | ទឹកប្រាក់ | ១០.៣២០ USD |

មាត្រា២ .-សហការដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធផលតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

***

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៨

### សេចក្តីសំរេចលេខ ២៩ សសរ

### ស្តីពីការផ្ទេរសិទ្ធិ

****

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៩៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-យោងតាមសំណូមពរការងារចាំបាច់ ។

### សំរេច

ប្រការ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម សុខ អាន សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អោយទទួលបន្ទុកបន្ថែមជារដ្ឋមន្ត្រីស្តីទី ក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម ចម ប្រសិទ្ធ ដែលត្រូវបានសុំលាលែងពីមុខតំណែង ។

ប្រការ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

***

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្តីសំរេចលេខ ៣០ សសរ

## ស្តីពីការលុបចោលសេចក្តីសំរេច ស្តីពីការកំណត់ថ្លៃជាវថាមពលអគ្គីសនី នៅក្នុងរាជធានីភ្នំពេញ

* * * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៧៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-តាមសភាពការណ៍ចាំបាច់ ។

### សំរេច

ប្រការ១ : ត្រូវបានលុបចោលសេចក្តីសំរេចលេខ ២៨ សសរ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការកំណត់ថ្លៃជាវថាមពលអគ្គីសនីនៅក្នុងរាជធានីភ្នំពេញ ដោយមូលហេតុ បច្ចេកទេស ។